ប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ **សម័យប្រឡង ២២ សីហា ២០២៥** **វិញ្ញាសារ៖ ជីវវិទ្យា (ថ្នាក់វិទ្យាសាស្ត្រ)** **រយៈពេល៖ ៩០នាទី ពិន្ទុ៖ ៧៥**	**សម័យប្រឡង**..... **មណ្ឌលប្រឡង**..... **លេខបន្ទប់**.....**លេខតុ**..... **ឈ្មោះបេក្ខជន**..... **ហត្ថលេខាបេក្ខជន**.....

I. (៥ពិន្ទុ) ក. តើអាស៊ីតអាមីណូពីរភ្ជាប់គ្នាដោយសារអ្វី? ចូរសរសេររូបមន្តស្ថេរាតនៃចំណងនេះ។

ខ. ចូរសរសេររូបមន្តស្ថេរាតនៃអាស៊ីតអាមីណូមួយ។

គ. ចូរសរសេររូបមន្តស្ថេរាតនៃឌីប៉ិបទីត។

II. (១០ពិន្ទុ) ក. ចូរពណ៌នាពីទីតាំងនិងនាទីរបស់អ៊ីប៉ូតាឡាមុស។

ខ. តើមានបញ្ហាអ្វីកើតឡើងនៅពេលខូចខាតខួរតូច?ចូរពន្យល់។

III. (១០ពិន្ទុ) ក. ចូរពន្យល់ពាក្យ : វិស្វកម្មសេនេទិច។

ខ. ចូរពណ៌នាពីរបៀបផលិតអរម៉ូនអាំងសុយលីនតាមវិស្វកម្មសេនេទិច។

IV. (១០ពិន្ទុ) ក. ដូចម្តេចដែលហៅថា ស្វ័យដំឡើងទ្វេ ADN ?

ខ. ចូរប្រៀបធៀប ADN និងប្រូតេអ៊ីន។

V. (១៥ពិន្ទុ) ម៉ូលេគុល ARNm មួយមានសមាសភាពរីបូនុយក្লេអូទីត A, U, G, C ដែលចែកជាសមាមាត្រតាមលំដាប់ដោយ 9 : 7 : 3 : 1 ។ ម៉ូលេគុល ARNm នេះមានប្រវែង 326.4nm។

ក. គណនាចំនួនរីបូនុយក្লេអូទីតប្រភេទនីមួយៗរបស់ ARNm ។

ខ. គណនាចំនួននុយក្লេអូទីតប្រភេទនីមួយៗរបស់សែនដែលកំណត់សំយោគARNm នេះ ។